# ខ្សែសង្វាក់នៃការចាប់ខ្លួនមនុស្សនៅក្រសួងការបរទេស

**(ចាន់ ប្រាថ្នា ៖ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២)**

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ គឺជាថ្ងៃទី៣ ដែលអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី រចឹម ទន់ ជាអតីតកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ម្នាក់នៅក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងសវនាការថ្ងៃទី៣នេះ សាក្សីផ្តល់សក្ខីកម្មអំពីរឿងរ៉ាវជាច្រើនដែលបានកើតឡើងនៅក្នុងក្រសួងការបរទេស ដែលពាក់ព័ន្ធនឹងខ្សែសង្វាក់នៃការចាប់ខ្លួនកម្មាភិបាល និងបុគ្គលិកនៅក្នុងក្រសួងមួយនេះ ។ សូមបញ្ជាក់ថា លោក រចឹម ទន់ ហៅ ភី ភួន ហៅ ចៀម អាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅភូមិកែប ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនៈគិរី ។ បច្ចុប្បន្នលោករស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ លោកចូលរួមក្នុងចលនាបដិវត្តចាប់ពីឆ្នាំ១៩៦៣ ហើយសម្រេចចូលព្រៃតស៊ូក្នុងឆ្នាំ១៩៦៦ ។ ក្នុងឆ្នាំ១៩៦៧ លោកបានជួប ប៉ុល ពត នៅមន្ទីរ១០០ និង អៀង សារី នៅមន្ទីរ១០២ ដែលមន្ទីរទាំងពីរនេះមានទីតាំងនៅខេត្តរតនៈគិរី ។ ក្នុងឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះបាទ នរោត្តម សីហនុ ចេញពីអំណាច លោកបានផ្លាស់ទីលំនៅមកស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដោយមានតួនាទីជានិរសាររបស់ ប៉ុល ពត ។ រហូតមកដល់ឆ្នាំ១៩៧៣ លោកបានមកស្នាក់នៅជាមួយ ប៉ុល ពត នៅមន្ទីរប-៥ ដែលមានទីតាំងក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ មន្ទីរនេះ គឺជាបញ្ជាការដ្ឋានទ័ពសមរភូមិជួរមុខទូទាំងប្រទេសកម្ពុជាដែលគ្រប់គ្រងលើសមរភូមិផ្សេងៗទៀតក្នុងការវាយយកទីក្រុងភ្នំពេញ ។ អំឡុងពេលនោះ លោក រចឹម ទន់ មានតួនាទីជានិរសារ និងជាកងការពារសន្តិសុខសម្រាប់ ប៉ុល ពត ។ ការងាររបស់លោកគឺបញ្ជូនសំបុត្រពី ប៉ុល ពត ប្រគល់ជូនមន្ទីរបញ្ជាការដ្ឋានសមរភូមិផ្សេងៗទៀតដែលដឹកនាំដោយ តាម៉ុក, សុន សេន, វ៉ន វេត, កុយ ធួន... និង នួន ជា (នៅមន្ទីរ៧៤, ស្ទឹងត្រង់) ។ បន្ថែមលើនេះ លោកត្រូវអមដំណើរ និងការពារសន្តិសុខជូនកិច្ចប្រជុំដែលធ្វើដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន និងមេដឹកនាំផ្សេងៗទៀត ដែលបានពិភាក្សាអំពីការវាយរំដោះយកទីក្រុងភ្នំពេញ និងការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោក រចឹម ទន់ ត្រូវបានចាត់តាំងឲ្យបំពេញការងារនៅក្រសួងការបរទេស(មន្ទីរប-១) ដោយមានតួនាទីជាអ្នកទទួល និងជូនដំណើរគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានទូទាំងប្រទេសកម្ពុជា ។ ជាងនេះទៅទៀត លោកបានអមដំណើរមេដឹកនាំជាន់ខ្ពស់របស់បក្សដូចជា ប៉ុល ពត, នួន ជា, អៀង សារី ចុះទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានជាញឹកញ៉ាប់ ។ ក្រៅពីនេះ លោកមានតួនាទីជានិរសារនាំសំបុត្រពី អៀង សារី ប្រគល់ជូនមេដឹកនាំផ្សេងទៀតដូចជា

ប៉ុល ពត (នៅមន្ទីរក-១) , នួន ជា (នៅមន្ទីរ ក-៣) , ខៀវ សំផន (ក្នុងឋានៈជាប្រធានមន្ទីរ៨៧០ បន្ទាប់ពី ឌឿន បាត់ខ្លួន) , វ៉ន វេត (នៅក្រសួងពាណិជ្ជកម្ម) និង សុន សេន (នៅក្រសួងការពារជាតិ) ។ ការងារសំខាន់មួយទៀតគឺលោកជាអ្នកនាំយកកម្មាភិបាល និងបុគ្គលិកនៅក្រសួងការបរទេស(អ្នកទោសដែលត្រូវបានគេសង្ស័យថាជាប់ខ្សែស្រឡាយ សេ. អ៊ី. អា ឬ កា. ហ្សេ. បេ ឬជា យួនឈ្លានពានទឹកដី) ក្រោមការណែនាំរបស់ អៀង សារី និង សូ ហុង ដើម្បីប្រគល់ជូនមន្ទីរ៨៧០ ។ គួររំឭកដែរថា លោក សូ ហុង ហៅ សា ឡុតបាន (ក្មួយរបស់ ប៉ុល ពត) ដែលជាអតីតអគ្គលេខាធិការក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះថា ចៀម (រចឹម ទន់) ដែលជាអនុប្រធានរបស់ខ្លួន គឺជាអ្នកនាំខ្លួនបុគ្គលដែលត្រូវបានចាត់ទុកថាមានសមាសភាពមិនល្អនៅក្នុងក្រសួងការបរទេសប្រគល់ជូនមន្ទីរ៨៧០ ។[1] ក្នុងឋានៈជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ លោក រចឹម ទន់ បានបំពេញការងារយ៉ាងស្អិតរមួតជាមួយថ្នាក់លើរបស់ខ្លួន ពោលគឺលោកបានទទួលការណែនាំពី អៀង សារី និង សូ ហុង ក្នុងការអនុវត្តការងាររបស់ខ្លួន ហើយលោកតែងតែរាយការណ៍ជាប្រចាំអំពីការងាររបស់ខ្លួនទៅ អៀង សារី ជារៀងរាល់ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ។

នៅចំពោះមុខអង្គជំនុំជម្រះ លោក រចឹម ទន់ បានស្រាយបំភ្លឺអំពីខ្សែសង្វាក់នៃការបញ្ជា និងការសម្រេចដែលនាំឲ្យមានការចាប់ខ្លួនកម្មាភិបាល និងបុគ្គលិកជាច្រើននៅក្រសួងការបរទេស ។ លោកបានរំឭកថា ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មានការចាប់ខ្លួនកម្មាភិបាល និងបុគ្គលនៅក្រសួងការបរទេសក្នុងទ្រង់ទ្រាយធំ ។ មូលហេតុនៃការចាប់ខ្លួននេះ គឺដោយសារមានការឆ្លើយដាក់ពីអ្នកទោសនៅមន្ទីរស-២១ ថា បុគ្គលទាំងនោះមានការជាប់ពាក់ព័ន្ធនឹងខ្សែរបស់ **សេ**. **អ៊ី**. **អា** ឬ **កា**. **ហ្សេ**. **បេ** ឬជា **យួន** ឈ្លានពានទឹកដី ។ លោក រចឹម ទន់ បញ្ជាក់ថា ចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរស-២១ ដែលមានការជាប់ពាក់ព័ន្ធនឹងបុគ្គលដែលធ្វើការនៅក្រសួងការបរទេស ត្រូវបាន កាំង ហ្កេកអ៊ាវ ហៅ ឌុច(ប្រធានមន្ទីរស-២១) ប្រគល់ជូនមន្ទីរ៨៧០ ហើយមន្ទីរនេះបញ្ជូនបន្តឲ្យក្រសួងការបរទេសដើម្បីឲ្យ អៀង សារី ពិនិត្យ ។ ការជូនដំណឹងពីមន្ទីរ៨៧០ ទៅ អៀង សារី អំពីបុគ្គលដែលមានសមាសភាពមិនល្អនៅក្រសួងការទេស គឺភាគច្រើនធ្វើឡើងដោយ ប៉ុល ពត និង នួន ជា ។ បន្ទាប់ពីទទួលបានបញ្ជីឈ្មោះបុគ្គលដែលមានសមាភាពមិនល្អទាំងនោះ អៀង សារី ជាអ្នកធ្វើការកំណត់អំពីអត្តសញ្ញាណ ដោយបញ្ជាក់ពីតួនាទី និងផ្នែកដែលបុគ្គលនោះទទួលបន្ទុកនៅក្នុងក្រសួងការបរទេស ។ បន្ទាប់មកបុគ្គលទាំងនោះនឹងត្រូវបានក្រសួងការបរទេសបញ្ជូនឲ្យអង្គភាពយោធា«យ-១០» ។ លោក រចឹម ទន់ បន្ថែមថា អង្គភាពយោធា«យ-១០»

---

១-អាចរកមើលបន្ថែមក្នុងព្រឹត្តបត្រសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពីទំព័រទី៨-២៩ ។ អាចរកបានក្នុងគេហទំព័រៈ http://d.dccam.org/Projects/ECCC_Trial_Observation/pdf/Observation_12.pdf

គឺជាអង្គភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ ។ អង្គភាពនេះដឹកនាំដោយ ហាន និង វ៉ាន់ ហើយទទួលបន្ទុកជាពិសេស គឺការពារសន្តិសុខជូនថ្នាក់មជ្ឈិម ។

ចំពោះវិធីសាស្រ្តក្នុងការចាប់ខ្លួនកម្មាភិបាល និងបុគ្គលនៅក្រសួងការបរទេស លោក រចឹម ទន់ បញ្ជាក់ថា នៅពេលមានការជូនដំណឹង ឬមានផែនការចាប់ខ្លួនបុគ្គលណាម្នាក់ បុគ្គលនោះនឹងត្រូវបានគេប្រាប់ជាមុនមិនឲ្យទៅណាឡើយ ពោលគឺត្រូវមានវត្តមាននៅក្នុងក្រសួង ។ បន្ទាប់មកបុគ្គលទាំងនោះនឹងត្រូវបាននាំខ្លួនទៅក្រៅបរិវេណក្រសួងដើម្បីប្រគល់ជូនអង្គភាពយោធា«យ-១០» ។ លោកបន្ថែមថា ជាទូទៅ អៀង សារី និង សូ ហុង ជាអ្នកណែនាំលោកឲ្យយកបុគ្គលដែលនឹងត្រូវចាប់ខ្លួន ចេញទៅក្រៅក្រសួង ដើម្បីប្រគល់ជូនអង្គភាពយោធា «យ-១០» នៅទីតាំងជាក់លាក់ណាមួយដែលបានកំណត់ទុកជាមុន ។ ពោលគឺអង្គភាពយោធា«យ-២១» កម្រមកចាប់ខ្លួនអ្នកទោសដោយផ្ទាល់នៅក្នុងក្រសួងណាស់ គឺរាល់ការចាប់ខ្លួនអ្នកទោសត្រូវធ្វើនៅក្រៅក្រសួង ។

ចុងក្រោយលោក រចឹម ទន់ បញ្ជាក់ថា បុគ្គលទាំងអស់ដែលត្រូវបានក្រសួងការបរទេសប្រគល់ជូនមន្ទីរ៨៧០តាមរយៈអង្គភាពយោធា«យ-១០» គឺមិនដែលមានបុគ្គលណាម្នាក់បានវិលត្រឡប់មកក្រសួងការបរទេសវិញឡើយ ពោលគឺបុគ្គលទាំងនោះបានបាត់ខ្លួនរហូត ។ មកដល់ចំណុចនេះ គប្បីរំឭកដល់សក្ខីកម្មរបស់លោក រចឹម ទន់ ដែលបានផ្តល់ជូនតំណាងសហព្រះរាជអាជ្ញា ខែល លីសាក់ នៅពេលចោទសំណួរពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំងនៅក្រសួងការបរទេស ។ ពេលនោះ តំណាងសហព្រះរាជអាជ្ញា បានដាក់បង្ហាញឯកសារកំណត់ហេតុកិច្ចប្រជុំសន្និបាតរបស់ក្រសួងការបទេសក្រោមអធិបតីភាពរបស់ អៀង សារី ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានកត់ត្រា និងសង្ខេបដោយ សូ ហុង ។ ក្នុងឯកសារនេះមាននិយាយអំពី**“ការបោសសម្អាត”** និង**“ការកម្ទេចខ្មាំង”** ដែលជាប់ពាក់ព័ន្ធនឹង **សេ、 អ៊ី、 អា, កា、 ហេ្យ、 បេ** និង **យួនឈ្លានពានទឹកដី** ដែលបានរាយការណ៍ដោយអង្គភាពក្រោមចំណុះរបស់ក្រសួងការបរទេស ។ លោករចឹមទន់បញ្ជាក់ថា នៅចុងបញ្ចប់នៃសន្និបាតនេះ អៀង សារី បានណែនាំឲ្យអង្គភាពក្រោមចំណុះក្រសួងការបរទេសទាំងអស់ ត្រូវបន្តបោសសម្អាតខ្មាំងដែលនៅសេសសល់ក្នុងអង្គភាពរបស់ខ្លួនឲ្យអស់ ។

ចប់

**អាចរកមើលលម្អិតបន្ថែមនៅក្នុងឯកសារ៖**

១- បទសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយលោក រចឹម ទន់ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ។ អាចរកបានក្នុងគេហទំព័រ ៖ http://d.dccam.org/Archives/Interviews/Sample_Interviews/Former_Kh_Rouge/Phi_Phuon.pdf

២- សវនាការស្តាប់សក្ខីកម្មរបស់សាក្សី រចឹម ទន់ នៅថ្ងៃទី២៥, ២៦, ៣០, ៣១ ខែកក្កដា និងទី០១ ខែសីហា ឆ្នាំ២០១២ ។ អាចមើលបានក្នុងគេហទំព័រ៖ http://www.cambodiatribunal.org/multimedia